**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

**រវាង**

## រោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក

**និង**

## តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ រោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក

# ស្ដីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី២២ ខែ ឧសភា ឆ្នាំ ២០២៣ វេលាម៉ោង១រសៀល នៅក្នុងរោងចក្រ រោងចក្រ ភី ភី អេស អ៊ី ស៊ី ឯ.ក មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិតប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះសម្ភារៈវត្ថុធាតុដើមនិងគ្មានការបញ្ជាទិញពីអតិថិជន ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន៦៥នាក់ រយៈពេលចំនួន១៤ថ្ងៃ គឺចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០២៣ រហូតដល់ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២៣ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្ដល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួលចំនួន១៥ ដុល្លាអាមេរិក ជូនកម្មករនិយោជិតម្នាក់ៗ ដែលបើកនៅក្នុងប្រាក់ខែ មិថុនា
នៅថ្ងទី ០៥ ខែ កក្កដា ឆ្នាំ ២០២៣ ។

អង្គប្រជុំបានចប់វេលាម៉ោង០២ និង ២០នាទី រសៀល នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និទស្នាល និង ក្រោមស្មារតីយោគយល់គ្នា និងការសហការយ៉ាងរលូន ។

ភ្នំពេញ.ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០២៣

**តំណាងកម្មករ**

គុញ គឹមឃុន    ជ៉ុង សំផុន្នី    សេង ស្រីពៅ    ពេញ ស្រីលាត

**ជ. នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ភី ភី អេស អ៊ី ស៊ី ឯ.ក
P P S E C COMPANY LIMITED
KINGDOM OF CAMBODIA

**ហ៊ើល សែន**